សាលាដំបូងខេត្តកណ្ដាល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

បានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
កណ្ដាល. ថ្ងៃទី០៩ ខែ 6 ឆ្នាំ ២០14
ក្រឡាបញ្ជី

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ១៣៦៧
ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩
សាលក្រមលេខ៖ ០៣ (ឆ.វ.ន)
ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្ដាល**

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅសាលាដំបូងខេត្តកណ្ដាលនា ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ វេលាម៉ោង ១០ ព្រឹកដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ១៣៦៧ អក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] ភេទប្រុស អាយុ២៦ ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិល្វាសរក្រោម ឃុំល្វាសរ ស្រុកល្វាឯម ខេត្តកណ្ដាល ឪពុកឈ្មោះ: [redacted] (ស) ម្ដាយឈ្មោះ: [redacted] (រស់) នៅលើវ។

ត្រូវបានជាប់ចោទពីបទ៖ ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅ [redacted] ខេត្តកណ្ដាល កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

មេធាវីការពារជនជាប់ចោទឈ្មោះ: [redacted]

**ដំណើរអង្គហេតុមានដូចតទៅ**

កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ វេលាម៉ោង០៩ និង៣០នាទីយប់ ស្ថិតនៅភូមិល្វាសរ ឃុំល្វាសរ ស្រុកល្វាឯម ខេត្តកណ្ដាល [redacted] បានធ្វើសកម្មភាពឡើងជួ:

I 10
25
25

Scanned by CamScanner

របស់ជនរងគ្រោះឈ្មោះ [redacted] ក្រោយពីជនសង្ស័យបានផឹកស្រាមានអាការៈស្រវឹងខ្លាំង ក៏បានដោះអាវស្រាតខោ នៅសល់តែខោលីអូ ដើរសំដៅមកផ្ទះជនរងគ្រោះ រួចឡើងតាមជណ្ដើរក្រោយ ដែលពុំមានទ្វារបិទបើក ដើរសំដៅមកគ្រែជនរងគ្រោះ ហើយធ្វើសកម្មភាពបើកមុង ធ្វើឲ្យជនរងគ្រោះ ភ្ញាក់ដឹងខ្លួន យកទូរស័ព្ទបុចភ្លើងមើលមុខ និងស្រែកឲ្យអ្នកជិតខាងគេមកជួយ ពេលនោះជនសង្ស័យក៏ស្ទុះរត់ចេញតាមជណ្ដើរក្រោយគេចខ្លួនបាត់តែម្ដង។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖ ៥០៦ ជកសព ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣។

បានឃើញ ដីកាបំណោះស្រាយលេខ៖ ៣២៨ ចុះថ្ងៃ០៨ ខែ កក្កដា ឆ្នាំ២០១៣។

បានឃើញ ចំណារចាត់តាំងទៅក្រុមជំនុំជម្រះ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣ ។

**នាពេលសវនាការ**

-អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថា៖ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ វេលាម៉ោង ០៩ និង៣០ នាទីយប់ ខ្លួនកំពុងដេកនៅលើផ្ទះ ដែលស្ថិតនៅភូមិស្វាស ឃុំស្វាស ស្រុកល្វាឯម ខេត្តកណ្ដាល ជាមួយក្មួយប្រុសពីរនាក់ឈ្មោះ [redacted] ០៩ឆ្នាំ និងឈ្មោះ [redacted] ស្រាប់តែលឺឆ្កែព្រុស បានលឺសំរឹបជើងមនុស្សឡើងផ្ទះ។ មួយសន្ទុះបានលឺសូរវាហៅខ្លួនថា យើៗ ហើយខ្លួនក៏បើកភ្នែកមើលឃើញតែស្រមោលមនុស្សព្រិលៗ ខ្លួនក៏បើកភ្លើងទូរស័ព្ទចាំងមើលមុខវាឃើញឈ្មោះ [redacted]ក្នុងមុងខ្លួនអត់ពាក់ខោអាវ ពាក់តែលីអូ មានខ្លិនស្រា ខ្លួនក៏រត់ចេញពីមុងទៅម្ខាងទៀតនៃផ្ទះ ស្រែកហៅឱ្យគេជួយថា អាធាឡើងផ្ទះខ្លួន ពេលនោះឈ្មោ[redacted] មិនដេញចាប់ខ្លួនទេ ហើយវានិយាយថា ម៉េចអញ្ចឹង។ ពេលនោះឈ្មោះ[redacted]ត្រូវជាមីងខ្លួន និងឈ្មោ[redacted]អ្នកជិតខាងមកដល់ផ្ទះខ្លួន រត់មកដល់ជិតជណ្ដើរ ឈ្មោ[redacted]នលោតចុះពីតាមក្រោយបាត់ទៅ។ ខ្លួនសុំទាមទារសំណងជម្ងឺចិត្ត ចំនួន ២០០០ ដុល្លាអាមេរិក (ពីរពាន់ដុល្លាអាមេរិក)។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] បានឆ្លើយថា៖ កាលពីថ្ងៃខែឆ្នាំកើតហេតុ ម៉ោងប្រហែល ៩ និង៣០នាទីយប់ ខ្លួនកំពុងដេកនៅលើផ្ទះដែលស្ថិតនៅទល់មុខផ្ទះឈ្មោ[redacted]ន លឺសំលេងរបស់ឈ្មោ[redacted] ស្រែកហៅខ្លួនឱ្យជួយវា ខ្លួនក៏ស្រែកហៅឈ្មោ[redacted] ជាក្មួយខ្លួនដែរ នៅផ្ទះជាប់ខ្លួន ឱ្យជួយឈ្មោះ[redacted] ខ្លួន និងឈ្មោះ [redacted] ក៏រត់ទៅផ្ទះឈ្មោះ[redacted]ពេលទៅដល់កាំជណ្ដើរផ្ទះឈ្មោះ[redacted]ខ្លួនស្រែកឱ្យវាបើកភ្លើង ឈ្មោះ [redacted]បើកភ្លើង ខ្លួនបានឃើញឈ្មោ[redacted]កទប្រុស កំពុងលោតចុះពីលើផ្ទះទៅតាមក្រោយផ្ទះបាត់ទៅ។

-អំណានចម្លើយសាក្សីឈ្មោះ[redacted]បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្លួនមិនបានឃើញឈ្មោ[redacted]ឡើងលើផ្ទះ រឺលោតចុះពីលើផ្ទះឈ្មោះ [redacted] ព្រោះខ្លួនទៅផ្ទះឈ្មោះ[redacted]ក្រោយឈ្មោះ [redacted] នៅថ្ងៃកើតហេតុខ្លួនគ្រាន់តែលឺឈ្មោះ [redacted]ស្រែកហៅខ្លួនឱ្យជួយឈ្មោះ[redacted]ជួយមី[redacted] ខ្លួនក៏ចុះពីលើផ្ទះទៅផ្ទះឈ្មោះ[redacted] មិនបានឃើញជនល្មើសទេ ឃើញតែឈ្មោ[redacted]ស្ថិតក្នុងលក្ខណៈភិតភ័យ។

Scanned by CamScanner

-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការៈ ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងអំណានចម្លើយសាក្សី តំណាងអយ្យការយល់ឃើញថា កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ពិតជាបានឡើងលើផ្ទះជនរងគ្រោះឈ្មោះ [redacted] ដើម្បីចាប់រំលោភឈ្មោះ [redacted] ប៉ុន្តែឈ្មោះ [redacted] បានភ្ញាក់ទាន់ និងបានស្រែកឱ្យគេជួយ ជនជាប់ចោទក៏លោតចុះតាមក្រោយផ្ទះរត់បាត់ ដែលអំពើនេះត្រូវបានចាត់ទុកថាជាបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិល្វាសរ ឃុំល្វាសរ ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ ហេតុដូច្នេះ តំណាងអយ្យការសូមរក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខៈ ៥០៦ ដកសព ចុះ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣ ទុកជាបានការទាំងស្រុង។

-សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទៈ ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងអំណានចម្លើយសាក្សី ខ្លួនជាមេធាវីការពារឱ្យជនជាប់ចោទស្នើសុំដល់តុលាការមេត្តាពិចារណា និងសម្រេចតាមច្បាប់។

ក្រោយពីបានស្ដាប់អំណានចម្លើយដើម្បីបណ្ដឹងរដ្ឋប្បវេណី

ក្រោយពីបានស្ដាប់អំណានចម្លើយសាក្សី

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

## សាលាដំបូងខេត្តកណ្ដាល

## យល់ឃើញថា

១.ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថាៈ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ វេលាម៉ោង ០៩ និង៣០ នាទីយប់ ខ្លួនកំពុងដេកនៅលើផ្ទះ ដែលស្ថិតនៅភូមិល្វាសរ ឃុំល្វាសរ ស្រុកល្វាឯម ខេត្តកណ្ដាល ពេលខ្លួនបើកភ្នែកមើល និងបើកភ្លើងទូរស័ព្ទចាំងមើល ឃើញ [redacted] ឯមុងខ្លួនអត់ពាក់ខោអាវ ពាក់តែលីអូ មានខ្លិនស្រា ខ្លួនក៏រត់ចេញពីមុងទៅម្ខាងទៀតនៃផ្ទះ ស្រែកហៅឱ្យគេជួយថា [redacted] ខ្លួន។ ពេលនោះឈ្មោះ [redacted] ត្រូវជាមីងខ្លួន និងឈ្មោះ [redacted] អ្នកជិតខាងមកដល់ផ្ទះខ្លួន រត់មកដល់ជិតជណ្ដើរ [redacted] បានលោតចុះដីតាមក្រោយបាត់ទៅ។

២.សាក្សីឈ្មោះ [redacted] បានឆ្លើយថាៈ កាលពីថ្ងៃខែឆ្នាំកើតហេតុ ម៉ោងប្រហែល ៩ និង៣០នាទីយប់ ខ្លួនកំពុងដេកនៅលើផ្ទះដែលស្ថិតនៅទល់មុខផ្ទះឈ្មោះ [redacted] បានលឺសំលេងរបស់ឈ្មោះ [redacted] ស្រែកហៅខ្លួនឱ្យជួយវា ខ្លួនក៏ស្រែកហៅឈ្មោះ [redacted] ត្រូវជាក្មួយខ្លួនដែរ នៅផ្ទះជាប់ខ្លួន ឱ្យជួយឈ្មោះ [redacted] ន និងឈ្មោះ [redacted] ក៏រត់ទៅផ្ទះឈ្មោះ [redacted] បទៅដល់កាំជណ្ដើរផ្ទះឈ្មោះ [redacted] បកឱ្យវាបើកភ្លើង [redacted]

Scanned by CamScanner

[redacted] ក៏បើកភ្លើង ខ្លួនបានឃើញឈ្មោះ [redacted] ប្រុស កំពុងលោតចុះពីលើផ្ទះទៅតាមក្រោយផ្ទះបាត់ទៅ។

៣.តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឯសាក្សីឈ្មោះ [redacted] អាចបញ្ជាក់បានថា កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ជនជាប់ចោទឈ្មោះ [redacted] ពិតជាមានចេតនាធ្វើសកម្មភាពឡើងទៅលើផ្ទះរបស់ជនរងគ្រោះ ដោយស្លៀកតែលីអូ និងបានចូលក្នុងម៉ុងរបស់ជនរងគ្រោះក្នុងគោលបំណងចាប់រំលោភជនរងគ្រោះ ប៉ុន្តែជនរងគ្រោះបានដឹងខ្លួនទាន់ ក៏បានស្រែកឱ្យគេជួយ ធ្វើឱ្យជនជាប់ចោទភ័យភ្លាច និងលោតចុះពីលើផ្ទះរត់បាត់ ដែលអំពើនេះច្បាប់ចាត់ទុកជាជាបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៤.អំពើរបស់ជនត្រូវចោទឈ្មោះ [redacted] បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ប៉ះពាល់ដល់កិត្តិយស និងរូបកាយរបស់ជនរងគ្រោះ ហើយជនត្រូវចោទ ជានីតិជនមានស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ។

៥.មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើ [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ ពីបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិល្វាសរ ឃុំល្វាសរ ស្រុកល្វាឯម ខេត្តកណ្តាល កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៦.អំពើរបស់ជនជាប់ចោទដែលតម្រូវឱ្យផ្តន្ទាទោសពីបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ តាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ គឺផ្តន្ទាទោសធ្ងន់ជាងអំពើ ប៉ុនប៉ងរំលោភសេពសន្ថវៈ តាមមាត្រា ២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។ ហេតុដូច្នោះតុលាការធ្វើការកែប្រែបទចោទប្រកាន់លើជនជាប់ចោទពីបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ ដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មកជាបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌវិញ។

៧.ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ បានរត់គេចខ្លួន ហើយអំពើរបស់ជនជាប់ចោទត្រូវផ្តន្ទាទោសដាក់ពន្ធនាគារលើសពីមួយឆ្នាំ តុប្បីសាលាដំបូងខេត្តកណ្តាលចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៨.ដើមបណ្តឹងរដ្ឋប្បវេណី [redacted] ស្នើសុំទាមទារសំណងជម្ងឺចិត្តចំនួន ២០០០ ដុល្លាអាមេរិក (ពីរពាន់ដុល្លាអាមេរិក) តុលាការនឹងធ្វើការពិចារណា និងសម្រេចតាមព្យសនកម្មជាក់ស្តែង។

Scanned by CamScanner

<u>**ហេតុដូច្នេះសម្រេចសេចក្តី**</u>

១/កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ២៦ ឆ្នាំ ជាតិខ្មែរ ពីបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មកជាបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា **២៧** និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

២/ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៥ (ប្រាំ) ឆ្នាំ ពីបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិល្វាសរ ឃុំល្វាសរ ស្រុកល្វាឯម ខេត្តកណ្តាល កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥ **បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស** តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

៣/ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ តាមមាត្រា **៣៥៣** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤/បង្គាប់ឱ្យឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ សងសំណងរដ្ឋប្បវេណីទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំនួន ៤,០០០,០០០ រៀល (បួនលានរៀល)។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនាថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ក្រុមប្រឹក្សាជំនុំជម្រះ | ក្រុមប្រឹក្សាជំនុំជម្រះ | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |

ច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើម

កណ្តាល, ថ្ងៃទី ២៤. ខែមករា ឆ្នាំ2014

ក្រឡាបញ្ជីសវនាការ

[redacted]

Scanned by CamScanner